ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

លេខៈ ០៥ អយក. ស៊ាខ

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មករា ឆ្នាំ២០១៦

## សូមជម្រាបមក
## ឯកឧត្តម លោក លោកស្រី ជាប្រធានអង្គភាពថវិកាមិនមែនអាណាប័កផ្ទេរសិទ្ធិ

**កម្មវត្ថុ៖** អនុញ្ញាតជាគោលការណ៍ផ្តល់សិទ្ធិសម្រេចជូនប្រធានអង្គភាពថវិកាមិនមែនជាអាណាប័កផ្ទេរសិទ្ធិ សម្រាប់ការចំណាយនិងការទូទាត់ប្រាក់វដ្ដទេយ្យបុរេប្រទាន។

**យោង ៖** ប្រកាសលេខ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមវដ្ដទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

តបតាមកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបឯកឧត្តម លោក លោកស្រី មេត្តាជ្រាបថា៖ តាមស្មារតីនៃប្រកាសលេខ១៩៣៧សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ត្រង់ផ្នែកទី២ (ការចំណាយ និងការទូទាត់ប្រាក់វដ្ដទេយ្យបុរេប្រទាន ) ដែលពាក់ព័ន្ធនឹងប្រការ១៥និង១៦ បានចែងថា៖

**-ប្រការ១៥៖** ជាគោលការណ៍វដ្ដទេយ្យបុរេប្រទាន ត្រូវចំណាយជាសាច់ប្រាក់ដោយមានសក្ខីប័ត្របញ្ជាក់ត្រឹមត្រូវ។ មុននឹងធ្វើការចំណាយជាសាច់ប្រាក់វដ្ដទេយ្យបុរេប្រទាន ត្រូវស្នើសុំគោលការណ៍ចំណាយទៅអាណាប័ក ឬអ្នកដែលទទួលបានការផ្ទេរសិទ្ធិពីអាណាប័ក។

**-ប្រការ១៦៖** រាល់ប័ណ្ណចំណាយ ត្រូវភ្ជាប់មកជាមួយនូវគោលការណ៍ចំណាយ វិក្កយប័ត្រ ឬសក្ខីប័ត្រចំណាយដែលវដ្ដទេយ្យករបុរេប្រទានបានធ្វើការទូទាត់ ដោយមានការបញ្ជាក់ទទួលស្គាល់ពីអាណាប័ក ឬអ្នកដែលទទួលបានការផ្ទេរសិទ្ធិពីអាណាប័ក។ តាមខ្លឹមសារនៃប្រការទាំងពីរគឺប្រធានអង្គភាពថវិកាមិនមែនអាណាប័កផ្ទេរសិទ្ធិគ្មានសិទ្ធិសម្រេចរាល់ការចំណាយតាមវដ្ដទេយ្យបុរេប្រទានទេ ដូចនេះដើម្បីជួយសម្រួលដល់ការអនុវត្តថវិកាឲ្យប្រព្រឹត្តដោយរលូននិងបង្កើនការទទួលខុសត្រូវកាន់តែច្បាស់លាស់នៅកម្រិតអនុវត្ត។

ក្រសួងសូមអនុញ្ញាតជាគោលការណ៍ផ្តល់ជូនដល់ប្រធានអង្គភាពថវិកាដែលមិនមែនជាអាណាប័កផ្ទេរសិទ្ធិ"**មានសិទ្ធិសម្រេចដូចខ្លឹមសារនៃប្រការទាំងពីរក្នុងប្រកាសលេខ១៩៣៧សហវ.ប្រក**" ក្នុងគោលបំណងបង្កើនប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃការចំណាយតាមវដ្ដទេយ្យបុរេប្រទានឲ្យមានលក្ខណៈទន់ភ្លន់ និងទាន់ពេលវេលា។

អាស្រ័យហេតុនេះ សូមឯកឧត្តម លោក លោកស្រី ជាប្រធានអង្គភាពថវិកាដែលមិនមែនអាណាប័កផ្ទេរសិទ្ធិ មេត្តាចាត់ចែងអនុវត្តឲ្យមានតម្លាភាពនិងគណនេយ្យភាព តាមការគួរ។

សូមលោក លោកស្រី ទទួលនូវការគោរពរាប់អានដ៏ស្មោះពីខ្ញុំ។

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

បណ្ឌិត ហង់ ជួន ណារ៉ុន

- ឯកសារ
- កាលប្បវត្តិ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទៈ (៨៥៥-២៣) ២១០ ១៨៧ /២១៧ ២៥៣ /៤២៦ ៩៥១ ទូរសារៈ (៨៥៥-២៣) ២១៧ ២៥០/ ២១២ ៥១២
អ៊ីមែលៈ info@moeys.gov.kh / crsmeys@camnet.com.kh គេហទំព័រ : www.moeys.gov.kh